# មេរៀនទី ១៤២: ព្រះអម្ចាស់លើកហោរាអេលីយ៉ាទៅស្ថានសួគ៌

## ២ ពង្សាវតាក្សត្រ ២:១-១៥

**គោលបំណង៖** ព្រះនឹងផ្តល់រង្វាន់ដល់អស់អ្នកដែលស្មោះត្រង់។

**ខគម្ពីរចងចាំ៖ ២ កូរិនថូស ៥:៧** *“ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយមើលឃើញទេ។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ដូចអេលីយ៉ាដែរ ព្រះយេស៊ូវបានចាកចេញពីផែនដីនេះទាំងរស់។ ពេលព្រះយេស៊ូវចាកចេញទៅទ្រង់បានប្រគល់វិញ្ញាណបរិសុទ្ធរបស់ទ្រង់ដល់អ្នកដែលនឹងបន្តកិច្ចបម្រើរបស់ព្រះអង្គ។ ក្នុងនាមជាអ្នកដើរតាមព្រះ-យេស៊ូវ យើងក៏មានព្រះវិញ្ញាណបរិសុទ្ធហុំព័ទ្ធយើង ដោយការពេញចិត្តនិងអំណាចរបស់ទ្រង់! ក្នុងពេលនោះអេលីសេបានសន្យានូវភាពស្មោះត្រង់របស់គាត់ចំពោះអេលីយ៉ាបីដង។ សូមចំណាយពេលបន្តិចក្នុងការអធិស្ឋានដើម្បីបង្ហាញការតាំងចិត្តរបស់អ្នក ក្នុងការធ្វើតាមនិងបម្រើព្រះគ្រីស្ទ។ បន្ទាប់មកសូមសុំព្រះយេស៊ូវឲ្យផ្តល់អំណាចដល់អ្នក ដើម្បីរក្សាការប្តេជ្ញាចិត្តរបស់អ្នក ហើយបម្រើគ្រប់ផែនការរបស់ទ្រង់នៅលើផែនដីនេះ។

**ចំរៀង៖** ១.នៅស្ថានសួគ៌មានក្មេង ២.ខ្ញុំសប្បាយរីករាយ ៣.ខ្ញុំសូមលើកព្រះនាមទ្រង់ឡើង

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ធ្វើកាយវិការផ្ទុយ»**



១. ឲ្យកុមារឈរជា២ ឬ ៣ ជួរ។

២. នៅពេលដែលគ្រូនិយាយថា “ស្តាំ” ពួកគេត្រូវតែលោតទៅស្តាំ។ ដូចគ្នាដែរ ប្រសិនបើគ្រូនិយាយថា “ឆ្វេង” “ទៅមុខ” “ទៅក្រោយ” ពួកគេត្រូវធ្វើតាម។

៣. នៅពេលដែលកុមារគ្រប់គ្នាចងចាំហើយ គ្រូត្រូវប្រាប់ឲ្យកុមារធ្វើផ្ទុយម្តង។ ឧទាហរណ៍៖នៅពេលដែលគ្រូនិយាយថា “ស្តាំ” កុមារទាំងអស់គ្នាត្រូវលោតទៅឆ្វេង។ ហើយនៅពេលដែលគ្រូនិយាយថា “ឆ្វេង” ពួកគេត្រូវលោតទៅស្តាំវិញ។

៤. នៅពេលដែលកុមារណាធ្វើខុសពួកគេត្រូវអង្គុយចុះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ការធ្វើតាមការណែនាំ គឺពិតជាមានសារៈសំខាន់ណាស់។ ហើយព្រះនិងផ្តល់រង្វាន់ដល់អស់អ្នកណាដែលដើតាមការណែនាំរបស់ទ្រង់។

**៤. ការណែនាំមេរៀន**

តើអ្នកមានជំនឿលើឪពុកម្តាយរបស់អ្នកដែរឬទេ? តើពាក្យថាមានជំនឿមានន័យដូចម្តេច? គឺមានន័យថាអ្នកជឿទុកចិត្តលើបុគ្គលម្នាក់នោះថាតែងតែធ្វើល្អចំពោះអ្នក ហើយអ្នកតែងតែធ្វើតាមបុគ្គលម្នាក់នោះ។ តើអ្នកមានជំនឿលើព្រះដែរឬទេ? តើអ្នកជឿថាព្រះតែងតែធ្វើល្អដាក់អ្នកដែរឬទេ ហើយអ្នកនឹងដើរតាមទ្រង់ដែរឬទេ? នៅពេល

ដែលយើងមានសេចក្ដីជំនឿចំពោះព្រះ នោះទ្រង់នឹងផ្ដល់រង្វាន់សម្រាប់យើង។ ថ្ងៃនេះយើងនឹងរៀនពីបុរសពីរនាក់ដែលទទួលបានរង្វាន់ដោយសារតែសេចក្ដីជំនឿដែលពួកគាត់មានចំពោះព្រះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅទីនេះមានហោរាម្នាក់ឈ្មោះថា អេលីយ៉ា។ អេលីយ៉ាមានសេចក្ដីជំនឿ ហើយព្រមធ្វើនូវអ្វីគ្រប់យ៉ាងដែលព្រះសុំឲ្យគាត់ធ្វើ។ គាត់បានបង្ហាញពីព្រះចេស្ដារបស់ព្រះ ថែមទាំងបានជំទាស់ជាមួយហ្វឹងហោរាក្លែងក្លាយដែលថ្វាយបង្គំព្រះបាលទៀតផង។ ហើយនៅទីនោះក៏មានបុរសម្នាក់មានឈ្មោះថា អេលីសេ គឺជាអ្នកដែលស្រលាញ់ព្រះ និងបម្រើលោកអេលីយ៉ា។ ព្រះបានតែងតាំងអេលីសេឲ្យធ្វើជាហោរា ដែលធ្វើកិច្ចការបន្ដពីលោកអេលីយ៉ា។

ដោយព្រោះតែអេលីយ៉ាមានភាពស្មោះត្រង់ជាមួយព្រះ ទ្រង់ចង់លើកលោកអេលីយ៉ាទៅឋានសួគ៌ដើម្បីផ្ដល់រង្វាន់ដល់គាត់។ ព្រះទ្រង់នឹងប្រទានរង្វាន់ដល់អស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់។ អេលីសេចង់បម្រើព្រះដូចជាអ្វីដែលអេលីយ៉ាបានធ្វើ។ អេលីយ៉ាបានប្រាប់ទៅអេលីសេថា ប្រសិនបើអេលីសេឃើញព្រះលើកគាត់ទៅឯស្ថានសួគ៌ នោះមានន័យថាគាត់សមតាមបំណងប្រាថ្នារបស់គាត់ហើយ។ នៅពេលដែលអេលីយ៉ា និងអេលីសេកំពុងដើរ ព្រះក៏បានលើកអេលីយ៉ាទៅឯស្ថានសួគ៌ដោយរថជាភ្លើង។

អេលីសេបានរស់នៅជាមួយអេលីយ៉ាដោយជំនឿ និងបានឃើញការដែលអេលីយ៉ាឡើងទៅស្ថានសួគ៌ ព្រះក៏បានប្រទានរង្វាន់ដល់គាត់។ នៅពេលដែលអេលីយ៉ាឡើងទៅស្ថានសួគ៌ ក្រមារបស់គាត់ក៏បានធ្លាក់មកលើអេសេ។ អេលីសេក៏បានរើសវាឡើង។ អេលីសេក៏បានវាយទឹកដោយក្រមានោះ ហើយទឹកក៏ញែកជាពីរដូចជាអ្វីដែលលោកម៉ូសេបានធ្វើនៅឯសមុទ្រក្រហមអីចឹង។

ព្រះបានប្រទានរង្វាន់ដល់អេលីយ៉ាសម្រាប់សេចក្ដីជំនឿរបស់គាត់ តាមរយៈការដែលលើកគាត់ទៅឯនគរឋានសួគ៌។ ព្រះបានប្រទានរង្វាន់ដល់អេលីសេតាមរយៈសេចក្ដីជំនឿរបស់គាត់ ដោយផ្ដល់ឲ្យគាត់នូវទ្វេដង នៃព្រះវិញ្ញាណបរិសុទ្ធរបស់អេលីយ៉ា និងធ្វើឲ្យគាត់ក្លាយទៅជាអ្នកដឹកនាំដូចអេលីយ៉ាដែរ។ ទ្វេដងមានន័យថា អេលីសេមានអំណាចអាចធ្វើអ្វីៗសម្រាប់ព្រះច្រើនជាងការដែលអេលីយ៉ាធ្វើទៅទៀត។

សេចក្ដីជំនឿគឺជាផលផ្លែនៃព្រះវិញ្ញាណ។ វាគឺជាផ្នែកមួយដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងយើង ដើម្បីឲ្យយើងមានការលូតលាស់ឲ្យដូចជាទ្រង់។ ព្រះចង់ឲ្យយើងស្មោះត្រង់ដោយសារទ្រង់ស្មោះត្រង់។ ព្រះផ្ដល់រង្វាន់ និងប្រទានពរដល់យើង នៅពេលដែលយើងមានភាពស្មោះត្រង់ និងសេចក្ដីជំនឿ!

## ៦. សំនួរពិភាក្សា

១. តើនរណាខ្លះដែលជាហោរាស្មោះត្រង់នៅក្នុងរឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ? *អេលីយ៉ា និងអេលីសេ*

២. តើអេលីយ៉ាបានទទួលរង្វាន់នៃសេចក្ដីជំនឿ និងភាពស្មោះត្រង់របស់គាត់ដោយរបៀបណា?
*គាត់ត្រូវបានលើកឡើងទៅឯឋានសួគ៌ដោយរថជាភ្លើង*

៣. តើអេលីសេទទួលបានរង្វាន់នៃភាពស្មោះត្រង់របស់គាត់ដោយរបៀបណា?
*គាត់គឺទទួលបានអំណាចនៃព្រះវិញ្ញាណបរិសុទ្ធពីអេលីយ៉ាទ្វេដង*

៤. តើព្រះនឹងធ្វើដូចម្ដេចចំពោះអ្នកដែលមានសេចក្ដីជំនឿចំពោះទ្រង់? *ទ្រង់នឹងផ្ដល់រង្វាន់ដល់ពួកគេ*

៥. តើយើងអាចបង្ហាញសេចក្តីជំនឿដែលយើងមានចំពោះព្រះដោយរបៀបណា?
*ស្តាប់បង្គាប់ព្រះ ដើរតាមទ្រង់ ធ្វើការជ្រើសរើសឲ្យបានត្រឹមត្រូវ។ល។*

## ៧. ល្បែងកំសាន្ត «ទឹក គោក អាកាស»



១. ឲ្យកុមារឈរជារង្វង់ ហើយគ្រូនៅក្នុងរង្វង់នោះធ្វើជាអ្នកចាំទីមុន។
២. គ្រូត្រូវដើក្នុងរង្វង់នោះដោយនិយាយពាក្យថា "ទឹក គោក អាកាស"។ នៅពេលដែលគ្រូចង្អុលកុមារណាម្នាក់ កុមារនោះត្រូវនិយាយឈ្មោះសត្វមួយ ដែលរស់នៅក្នុងបរិយាកាសដែលគ្រូបានរើស។ ឧទាហរណ៍៖ ប្រសិនបើគ្រូនិយាយថា "គោក" នោះកុមារត្រូវហៅឈ្មោះសត្វមួយដែលរស់នៅលើគោក។ ប្រសិនបើគ្រូនិយាយថា "អាកាស" កុមារត្រូវហៅឈ្មោះសត្វដែលរស់នៅក្នុងអាកាស។
៣. ប្រសិនបើកុមារមិនអាចហៅឈ្មោះសត្វមួយណាបានក្នុងរយៈពេល ៣វិនាទី កុមារនោះនឹងចាញ់ល្បែងនេះ។
៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ទោះបីជាសព្វថ្ងៃនេះយើងរស់នៅក្នុងផែនដីក៏ដោយ យើងនឹងទៅឯនគរស្ថានសួគ៌នៅពេលដែលព្រះត្រាស់ហៅយើង។ រហូតពេលនោះមកដល់ យើងត្រូវស្មោះត្រង់ដូចអេលីយ៉ា និងអេលីសេ ដើម្បីឲ្យយើងអាចទទួលបានរង្វាន់ពីព្រះ។

## ៨. ខគម្ពីរចងចាំ ២ កូរិនថូស ៥:៧

## ៩. ហត្ថកម្ម «ព្រះអម្ចាស់លើកហោរាអេលីយ៉ាទៅស្ថានសួគ៌»

**សម្ភារៈដែលត្រូវការ៖** ព្រីនក្រដាសហត្ថកម្ម កន្ត្រៃ កូល័រ និងការបិត



១.ផាត់ពណ៌រូបរបស់អេលីយ៉ាជាមួយរថជាភ្លើង ហើយកាត់វាចេញមក។
២. សូមបិតរូបអេលីយ៉ាភ្ជាប់គ្នា ហើយបត់ត្រង់ចំណុចបន្ទាត់ដាច់ៗនៅចន្លោះរូបសេះ(តែកុំបិតរូបសេះ)។



៣. សូមពន្យល់កុមារថា ព្រះតែងតែផ្តល់រង្វាន់ដល់យើងនៅពេលដែលយើងមានភាពស្មោះត្រង់។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះអម្ចាស់លើកហោរាអេលីយ៉ាទៅស្ថានសួគ៌

